# ស្ថានទូតអូស្ត្រាលី ភ្នំពេញ

## <u>សេចក្តីប្រកាសពត៌មាន</u>

## **អូស្ត្រាលីជួយដល់កម្ពុជា ក្នុងនាមជាប្រធានសមាគមន៍អាស៊ាន តាមរយៈការបណ្តុះបណ្តាលភាសាអង់គ្លេសសំរាប់មន្ត្រីរាជការ**

នាថ្ងៃច័ន្ទ ទី21 ខែឧសភា ឆ្នាំ2012 ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា លោកជំទាវ **ផេននី រីឆាដស៍** (Penny Richards) និងឯកឧត្តម **ជេត ណារ៉ែន** អគ្គនាយក នៃអគ្គនាយកដ្ឋានអាស៊ាន ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានប្រគល់លិខិតបញ្ជាក់ការសិក្សាដល់មន្ត្រីរាជការចំនួន 33 នាក់ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីអបអរន្ទេវការបញ្ចប់វគ្គបណ្តុះបណ្តាលជំនាញភាសាអង់គ្លេសពិសេស ដែលបានធ្វើឡើងនៅមជ្ឈមណ្ឌលអូស្ត្រាលីសំរាប់ការបណ្តុះបណ្តាល (ACE) ។ វគ្គបណ្តុះបណ្តាលនេះត្រូវបានរៀបចំឡើងដោយមានការឧបត្ថម្ភរបស់រដ្ឋាភិបាលអូស្ត្រាលី តាមរយៈទីភ្នាក់ងារជំនួយអភិវឌ្ឍន៍អន្តរជាតិអូស្ត្រាលី (AusAID) ដើម្បីលើកកម្ពស់សមត្ថភាពជំនាញភាសាអង់គ្លេស ជូនមន្ត្រីដែលបំរើការងារពាក់ព័ន្ធនឹងកិច្ចប្រជុំអាស៊ាននាឆ្នាំនេះ។

ប្រទេសកម្ពុជា ដែលជាប្រធានសមាគមអាស៊ាននាឆ្នាំ 2012 នេះ នឹងដឹកនាំកិច្ចប្រជុំអាស៊ាន និងកិច្ចប្រជុំពាក់ព័ន្ធនឹងសមាគមអាស៊ានជាច្រើន រួមទាំងកិច្ចប្រជុំកំពូលអាស៊ីបូ៉ា និងវេទិកាអាស៊ានថ្នាក់តំបន់ជាដើម។ អូស្ត្រាលីដែលជាដៃគូដ៏យូរអង្វែងរបស់អាស៊ាន មានមោទនភាពក្នុងការចូលរួមជួយគាំទ្រកម្ពុជាក្នុងការបំពេញនូវតួនាទីជាប្រធានសមាគមនេះ។ អូស្ត្រាលីបានក្លាយជាដៃគូរបស់អាស៊ានចាប់តាំងពីឆ្នាំ 1974 ។ អូស្ត្រាលីបានចូលរួមចំណែកក្នុងការស្ថាបនានូវសំណង់ស្ថាបត្យកម្មតំបន់មួយ ដែលមានអាស៊ានជាស្នូល។

លោកជំទាវ **រីឆាដស៍** បានមានប្រសាសន៍ថា «យើងយល់ថា ក្នុងនាមជាប្រធានអាស៊ាន ប្រទេសកម្ពុជានឹងត្រូវទទួលបន្ទុកយ៉ាងធ្ងន់ធ្ងរក្នុងឆ្នាំនេះ ទាំងការងារពិធីការ និងភស្តុភារ ក៏ដូចជាការពង្រាងឯកសារ និងការរៀបចំឯកសារគោលនយោបាយដែលជាលទ្ធផលនៃការពិភាក្សា។ ភាសាអង់គ្លេស គឺជាភាសាការងាររបស់អាស៊ាន ។ ជំនាញភាសាអង់គ្លេស ជាជំនាញមិនអាចខ្វះបានក្នុងការបំពេញការងារពាក់ព័ន្ធទាំងនេះ ។ ដូច្នេះ យើងខ្ញុំពិតជាមានសេចក្តីរីករាយដោយបានជួយដល់មន្ត្រីក្រសួងការបរទេស និងកិច្ចសហប្រត្តិបត្តិការអន្តរជាតិ ក្នុងការលើកកម្ពស់ជំនាញ

16B National Assembly Street, Sangkat Tonle Bassac Khan Chamkamon, Phnom Penh City, Kingdom of Cambodia
Telephone: 855 23 213470 Facsimile: 855 23 213413

ភាសាអង់គ្លេសរបស់ពួកគេ ដើម្បីអោយអាចប្រើប្រាស់បានល្អក្នុងពេលកិច្ចប្រជុំអាស៊ានក្នុងឆ្នាំនេះ ក៏ដូចជានៅពេលអនាគត។»

នាឆ្នាំ 2010-11 ពាណិជ្ជកម្មសរុបរវាងអូស្ត្រាលី និងតំបន់អាស៊ានទាំងមូលមានទំហំរហូតដល់ 82.9 ពាន់លានដុល្លាអូស្ត្រាលី។ ហើយនាឆ្នាំ 2011-12 អូស្ត្រាលីបានផ្តល់នូវជំនួយអភិវឌ្ឍន៍សរុបជាង 1 ពាន់លានដុល្លាអូស្ត្រាលី ដល់សមាគមអាស៊ាន ។

ស្ថានទូតអូស្ត្រាលីសូមចូលរួមជួយអបអរដល់មន្ត្រីរាជការទាំង 33 រូប នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដែលបានបញ្ចប់នូវវគ្គបណ្តុះបណ្តាលជំនាញភាសាអង់គ្លេសនេះ ប្រកបដោយជោគជ័យ និងរំពឹងបន្តសហការជាមួយប្រទេសកម្ពុជា ដើម្បីធ្វើឲឆ្នាំដែលកម្ពុជាធ្វើជាប្រធានសមាគមអាស៊ាន ជាឆ្នាំដែលជោគជ័យ និងទទួលបាននូវផ្លែផ្កាគួរឲកត់សម្គាល់៕

<u>ពិធីនេះបានប្រព្រឹត្តទៅ</u>

ទីកន្លែង: ស្ថានទូតអូស្ត្រាលី

កាលបរិច្ឆេទ: ថ្ងៃច័ន្ទ ទី 21 ខែ ឧសភា ឆ្នាំ 2012 វេលាម៉ោង 1000- 1100

**ទំនាក់ទំនងពត៌មាន៖ លោក ដេវ ហ្គុចដ៍ អ្នកនាំពាក្យប្រចាំស្ថានទូតអូស្ត្រាលី**

**លេខទូរស័ព្ទ 023 213 470**

**ស្ថានទូតអូស្ត្រាលី ភ្នំពេញ**

**ថ្ងៃទី 21 ខែ ឧសភា ឆ្នាំ 2012**